រើសអើងពូជសាសន៍-អច្ចន្ត្ពិនិយម

Discrimination raciale et extrémisme

មាន ទស្សនៈ ខ្មែរមួយក្រុម ជា ពិសេស លោក កឹម សុខា យល់ឃើញថា បើមាន កលហពិរោធ និង ទោសៈ នឹងយួន ហួសហេតុ ពេក វាជា អច្ចន្ត្ពិនិយម[1]។ ពិតប្រាកដណាស់ថា អ្វីដែលជា អភិមាន[2] វាជា គំនិតជ្រុលនិយម តែ ការវាយតម្លៃ ថាវាជា ការពិត ឬ មិនពិត វា អាស្រ័យទៅលើ បរិបទ នៃ ស្ថានភាព នៃ ប្រជាជាតិខ្មែរ។ សព្វថ្ងៃ ស្រុកខ្មែរ ទទួលរងនឹង នយោបាយ រាតទឹកដី ពីសំណាក់វៀតណាម តាម មធ្យោបាយ បញ្ជូន ប្រជាជនយួន រាប់លាននាក់ មករស់នៅស្រុកខ្មែរ ដោយមាន ការយល់ព្រមពី រដ្ឋាភិបាលដឹកនាំដោយ លោក ហ៊ុន សែន។ នៅក្នុង បរិបទ បែបនេះ ដែលនាំអោយ ប្រជាជនខ្មែរ ក្លាយជា អ្នករងគ្រោះ ខ្វះមធ្យោបាយ ជួនលួម សំរាប់ ការពារ សិទ្ធិ របស់ខ្លួន ជា ប្រជាពលរដ្ឋខ្មែរ។ មធ្យោបាយបោះឆ្នោត វាគ្រាន់តែជា មាយាការ[3] នៃការប្រើសិទ្ធិ ជាពលរដ្ឋ នៅក្នុងប្រទេស គ្មានឯករាជ្យពិតប្រាកដ និង ដឹកនាំដោយ របបផ្តាច់ការ។ ការបោះឆ្នោត ថ្មីៗ នេះ គណបក្សសង្គ្រោះជាតិ បានឈ្នះមួយចំនួនធំដែរ នូវ ទីព្រឹក្សាឃុំ-សង្កាត់។ តែជ័យជំនះនោះ វានៅឆ្ងាយណាស់ពីបញ្ហា

---

[1] អច្ចន្ត្ពិនិយម; គំនិតជ្រុលនិយម។

[2] អភិមាន; សេចក្តីព្រហើន, សេចក្តីមើលងាយគេក្រៃពេក។

[3] មាយាការ ; សេចក្តីភាន់, ច្រឡំគំនិត ; illusion។

ខ្មែរ (enjeux) ព្រោះថា ពេលវេលា វាកំពុងធ្វើការ អោយយួន មិនតែប៉ុណ្ណោះ ជ័យជំនះនោះ វាជាំង នូវការពិត ដ្បិត ក្នុងនោះ វាជា មហាគ្រោះថ្នាក់ ដល់ប្រជាជាតិខ្មែរ ព្រោះ នៅក្នុង ឃុំ-សង្កាត់ ដែល គណបក្សសង្គ្រោះជាតិឈ្នះនោះ វាជា ការទទួលស្គាល់ នៃ អត្តភាព ពេញច្បាប់ នៃ អាណិកជនយួន ដែលមានសញ្ជាតិកម្ពុជា ខុសត្រូវច្បាប់ក្តី នៅក្នុង ឃុំ-សង្កាត់ មានជ័យ របស់ខ្លួន។ ដូច្នេះ ជ័យជំនះ ជា ចំនួន ឃុំ-សង្កាត់ របស់ បក្សសង្គ្រោះជាតិ វាជា ជ័យជំនះ ជា ដំណាក់ការ មួយជំហ៊ានលោតផ្លោះ នៃ នយោបាយ វាតទឹកដី របស់វៀតណាម នោះឯង គឺថា ខ្មែរ ឈ្នះកៅអី រីឯយួនវិញ ឈ្នះទឹកដី។ ត្រូវដឹងថា យួន យក ជំហ៊ានលោតផ្លោះ ជា ខ្នាត សំរាប់វាស់ ដំណាក់ការ នយោបាយ លួចទឹកដីខ្មែរ ខណៈនោះដែរ ពួកអ្នកដឹកនាំគណបក្សសង្គ្រោះជាតិ យក ចំអាមដៃ ជាខ្នាត សំរាប់វាស់ជ័យជំនះកៅអី របស់ បក្សខ្លួន ហើយ នាំគ្នា ដើរ ពីមពើម ទៅមុខថយក្រោយ ជាពនេចរ លើផ្លូវយុទ្ធសាស្ត្រយួន។ នាយកធម៌ នៃ ពួកអ្នកដឹកនាំ គណបក្សសង្គ្រោះជាតិ សព្វថ្ងៃ មានកំរិត ក្រឹមតែដេកចាំបោះឆ្នោតបញ្ជោតរាស្ត្រ និងឈ្លោះប្រកែកគ្នាឯង គ្មានទីបញ្ចប់ តួយ៉ាង លោក សម រង្សី សួម លាលែងដំណែងពី ប្រធាន និង សមាជិកគណបក្ស ដោយហេតុផ្ទាល់ខ្លួន តែបន្ទាប់មក បែរជា ទាមទារតួនាទី ជា បេក្ខជន នាយករដ្ឋមន្ត្រី របស់គណបក្ស សំ រាប់ ការបោះឆ្នោតជាតិ នៅឆ្នាំ ២០១៨។ ភាពច្រាសច្រាលចិត្ត បែបនេះ វាគ្មានបង្ហាញអ្វីសោះ នូវកំនិតរៀសរបស់គាត់ ជា

មគ្គនាយកជាតិ មានការទទួលខុសត្រូវ[4]។ រីឯ លោក កឹម សុខា វិញ គាត់ លុប លោក សម រង្សី ចោល តាម អធិបញ្ញា របស់ លោក ហ៊ុន សែន ដើម្បី សេចក្តីសុខផ្ទាល់ខ្លួន។ ចំណែក អស់អ្នកដឹកនាំថ្នាក់រង វិញ ពួកគាត់ ជ្រើសយក ជនណាម្នាក់ ជាមេពួកគាត់ ដែលជាជន ដែល លោក ហ៊ុន សែន ជ្រើសរើស អោយ។ ដូច្នេះ ទាំងមេទាំងពង គឺ នាំគ្នាទុក លោក ហ៊ុន សែន ជា ព្រះបាទធម្មិក ជា ព្រះ សង្គ្រោះ គណបក្សសង្គ្រោះជាតិ។ ទាំង មេទាំងពង នាំគ្នា រៀបចំបោះឆ្នោតថ្នាក់ជាតិ នៅឆ្នាំ ២០១៨ ក្នុង ស្ថារតី ផ្សះផ្សាជាតិ សំរាប់ យួន ត្រួតត្រាប្រជាជាតិខ្មែរ។

នៅក្នុងស្ថារតី ផ្សះផ្សាខ្មែរ នេះឯង ដែល គណបក្សកាន់អំណាច និង គណបក្សប្រឆាំង(?) គេនាំគ្នា បង្កើត ផែនដីនយោបាយ (espace politique) មួយ សំរាប់ រក្សា ស្ថិរភាព នៃ សហវិជ្ជមាន របស់ពួកគេ ហើយ គេនាំគ្នា ទុក មនុស្សណា ឬ ក្រុមណា នៅ ក្រៅផែនដីនោះ ជា អ្នក (ពួក) អច្ចន្ទិនិយម ចំពោះមុខ ពួកគេ និង ជា អ្នក (ពួក) ប្រកាន់ជាតិសាសន៍ ចំពោះមុខ ជនជាតិ យួនរាប់លាននាក់ មករស់នៅស្រុកខ្មែរ។ នៅក្នុង ផែនដី នយោបាយ គណបក្សទាំងពីរ នាំគ្នាអនុវត្ត កម្មវិធីសំខាន់ ពីរ យ៉ាង នៅក្រោម អនុសាសន៍យួនៈ អន្តរប្រតិបត្តិការកិច្ច និង ស្វ័យភាព នៃយុទ្ធសាស្ត្រ[5]។ អន្តរប្រតិបត្តិការកិច្ច សំរាប់ កសាង

[4] មគ្គនាយកជាតិទទួលខុសត្រូវ ; dirigeant national responsable.
[5] អន្តរប្រតិបត្តិការកិច្ច, ស្វ័យភាព នៃយុទ្ធសាស្ត្រ ; interopératibilité, autonomie stratégique.

សាមគ្គីភាព រវាង បក្សនឹងបក្ស ក្នុង ក្រមខណ្ឌ ចោះឆ្នោត សិប្បនិម្មិត។ គេនាំគ្នា កសាង បន្ដិចម្ដងៗ ទូរ ស្ដង់ដារ សកម្មភាព និង វាក្យសព្ទ នយោបាយ សំរាប់ ប្រឆាំងនឹង សត្រូវនយោបាយ ឬអ្នក(ពួក) ដែលនៅក្រៅផែនដីនយោបាយ របស់ពួកគេ ដូចយ៉ាង សហការ នៅ សភាជាតិ, អនុវត្ត រ៉ាប្ចាធម៌ សន្ទនា, ប្រើ ពាក្យ ការពារ សន្ដិភាព, ពាក្យផ្សះផ្សាខ្មែរ, ពាក្យ អ្នក(ពួក) អច្ចន្ដិនិយម, ប្រកាន់ជាតិសាសន៍... ។ល។ តែកម្មវិធី សំខាន់ គឺ ស្វ័យភាព នៃយុទ្ធសាស្ត្រ ព្រោះជាយុទ្ធសាស្ត្រ សំរាប់ ចោកប្រាស់ប្រជាពលរដ្ឋ នៅពេល យុទ្ធការ នៃ ការចោះឆ្នោត។ ខាង គណបក្សសង្គ្រោះជាតិ គេ ប្រើ ពាក្យ យុទ្ធសាស្ត្រថ្មី គឺ ប្ដូរ ពាក្យ ស្លោកពី ‹ដូរឬមិនដូរ› ‹លោក ហ៊ុន សែន អើយ ចុះចេញ ទៅ› មកជា ‹ប្រកួនប្រជែង ដើម្បី បំរើប្រជាជន› ‹បើ លោក ហ៊ុន សែន ចាញ់ ធ្លាប់តម្រូវអោយ ចុះចេញពីតំណែង› រីឯខាង គណបក្សកាន់អំណាច វិញ គឺ ដើម្បី ការពារសន្ដិភាព។ តែតាម ការពិត ស្វ័យភាព នៃយុទ្ធសាស្ត្រ វាជា យុទ្ធសាស្ត្រ របស់យួន សំ រាប់ ក្ដាប ផែនដី នយោបាយ ដោយប្រើ លទ្ធិប្រជាធិបតេយ្យ ជាសំបក នៃ របបនយោបាយ តែនៅខាងក្នុងវិញ រដ្ឋខ្មែរ ស្ថិត នៅក្រោម អំណាចយួនទាំងអស់ ដែលមាន ជនយួន មាន សញ្ជាតិកម្ពុជា ជា អ្នកដឹកនាំ។ ហើយ ពី អាណត្ដិ មួយទៅ អាណត្ដិ មួយទៀត ឬសអំណាចយួន វាចាក់ស្រែះពេញស្រុកខ្មែរ។ ហៅ ជនយួន ថា យួន វា ក្លាយ ជា សម្ដី ‹រើសអើងពូជសាសន៍› ឬ ‹អសុរោះ›; និយាយថា អ្នកដឹកនាំខ្មែរសព្វថ្ងៃ ជា អាយ៉ងយួន

រាជ រាចា របស់ពួក អ្នកអច្ចន្ត្ពិនិយម; រៀបរាប់ថា មាន ជនយួន រាប់លាននាក់ នៅស្រុកខ្មែរ រាជ កំនិត ប្រឆាំងនឹង សន្ត្ពិភាព។ នៅក្នុងស្ការតី រក្សា ផែនដីនយោបាយរបស់យួន នៅស្រុកខ្មែរ លោក ហ៊ុន សែន គាត់ មានបំណង សរសេរ ប្រវត្ត្ពិសាស្ត្រ ជា អ្នកឈ្នះ ក្នុងហាន:ជា អ្នកបាត របស់យួន។ នៅក្នុងរឿងប្រឌិត ដោយអាលុលិក[6] របស់គាត់នោះ រាជ្ជាស់ជា សំយោគ នៃ ស្ងួយជីវ របស់គាត់ ជា អ្ការ នៃ អាយ៉ងយួន ក្រប់សម័យ គឺថា បើកូនខ្មែរ ចង់ដឹងថា មូលហេតុអ្វីបានជាយួន យកទឹកដីខ្មែរ បានងាយស្រួល គឺ ត្រូវនាំគ្នា អាន ស្ងួយជីវ សរសេរ ដោយ អ្នកឈ្នះ ហ៊ុន សែន គឺ ជ្ជាស់ជាយល់ ន្ទូវ ចិត្តកំនិត របស់ពួកខ្មែរ បំរើយួន ជាពុំខាន។ ក្នុង ស្ងួយជីវនោះ គឺជ្ជាស់ជា លោក ហ៊ុន សែន ទុកខ្មែរ អ្នកស្នេហាជាតិ ជា អ្នករើសអើងពូជសាសន៍ និង អ្នកអច្ចន្ត្ពិនិយម ដូចគ្នានឹងកំនិត របស់លោក កឹម សុខា នោះដែរ។

ប្រជាជាតិខ្មែរ សព្ទ្ធ្ជ ហេរទៅ១ មកពី មូលហេតុ នៃ សង្ក្ដាម និង សន្ត្ពិភាព ព្រោះថា តុល្យការ នៃ កត្ដាទាំងពីរ រ៉ា អវិជ្ជមាន គឺថា សង្ក្ដាម និង សន្ត្ពិភាព រ៉ា បំផ្លាញជាតិខ្មែរដូចគ្នា ព្រោះ អ្នកបង្កើតសង្ក្ដាម និង អ្នកឈ្នះសង្ក្ដាម រ៉ាជាតួតែមួយ គឺ រៀតណាម ចក្ក្ពត្ត្ពនិយម។ សន្ត្ពិភាព សព្ទ្ធ្ជ ជា ស្ងួកដែក សំរាប់ការពារវ៉ែរ ប្រយោជន៍យួន នៅស្រុកខ្មែរ រ៉ាក៏ជា មហោសថ

[6] រឿងប្រឌិត ដោយអាលុលិក ; histoire inventée grossièrement.

បន្ទាប នូវ ស្មារតី នៃ សេចក្ដីស្នេហាមាតុភូមិ របស់ខ្មែរ។ ស្មារតីនេះ ត្រូវ យួន និង ពួកខ្មែរ បំរើយួន គេ យក ទៅប្រដូចនឹងកំនិត រើសអើងពូជសាសន៍ និង អច្ចន្ត្ពិនិយម នៅស្រុកខ្មែរ ដែល របបដឹកនាំ រណបយួនសព្វថ្ងៃ គេ រក្សា ‹ការរូបសង្ក្រាម› ដើម្បី ក្ដាប់ ទឹកដី, ប្រាថ្នា ដឹកនាំបន្ដពូជ និង ឯការធិភាព នៃ អំពើហិង្សា ដែល ជា ការរូប ផ្ទុយស្រឡះ ពី ‹រដ្ឋមានសន្ដិភាព› ដែលជា នីតិរដ្ឋ។

សួរថា បើយួន នៅស្រុកខ្មែរ កំពុង ជាន់ពកខ្មែរ តើ អោយខ្មែរ អង្គុយចាំតែបោះឆ្នោត តាម ការប្រាថ្នា របស់អ្នកដឹកនាំ គណបក្សសង្ក្រោះជាតិ លើសពី គុណ្ណាបការខ្លួន គឺថា ឈ្នះ ក៏ យួន នៅ តែឈ្នះ ? ការអួតខ្លួន របស់ លោក កឹម សុខា ថា បក្សគាត់ឈ្នះ នឹងឈ្នះឆ្នោត បន្ដទៀត គឺជា អារម្មណ៍ នៃ ដំណើរចូលរួម ក្នុង នយោបាយយួន ឬ កំនិតច្របូកច្របល់ សំរាប់ប្រជាជាតិខ្មែរ។

ការទុកខ្មែរ អ្នកស្នេហាជាតិ ជា អ្នករើសអើងពូជសាសន៍ និង អ្នកអច្ចន្ត្ពិនិយម គឺ ជា កំនិត អោយខ្មែរ ចោះបង់ សិទ្ធិ ការពារ ប្រជាជាតិខ្លួន ក្នុងហាន:ជាពលរដ្ឋម្ចាស់ស្រុក នៅចំពោះមុខ អន្ដរាយ នៃ យួនូបណាយកម្ម នៃ ប្រជាជាតិខ្មែរ។ ការយល់ដឹង អំពី សេចក្ដីអន្ដរាយជាតិ គឺ ជា ទីដើម នៃ ដំណើរ នៃ កំនិត ស ង្ក្រោះជាតិ។ ជាបឋម វាជា កំនិតចង្អៀត មុននឹង រាតខ្លួន និង បែក ជាកម្លាំងជាតិ។ វាជា សក្ដាភាព អោយចិត្ដខ្លួន មាន ជោគជ័យ ហើយ រីកសាយពី ទីដើម ជា សក្ខីភាព (gage) ដែល

អាចជាហេតុ ដែលនាំ១ ប្រជាពលរដ្ឋខ្មែរជឿបាន។ បើ គំនិត សង្គ្រោះជាតិ ជា សក្ដាខ្ពង់ខ្ពស់ ប៉ុន្ដែអ្នកធ្វើ គ្មានយស ពុំស្ដើ ប្រជា ដែល គេគ្មានស័ក្ដិ គេគ្មានមេត្ដា សន្ទ្ធាជ្រះថ្លា ទេព្ពាស្ទ្ធា ញ់។ ដូច្នេះ ខ្មែរ អ្នកស្នេហាជាតិ ជា ប្រជា ពុំមែន ជា អ្នក រើសអើងពូជសាសន៍ និង អ្នកអច្ចន្ត្ដិនិយម ផ្ទុយទៅវិញ ជា ពលរដ្ឋ ទុក អំពើ ឃ្លានប្ដន់ ទឹកដីខ្មែរ ជា សង្គ្រោបមូល[7] នាំគ្នា ក្រើកចិត្ដ ដើម្បី តស៊ូ សង្គ្រោះជាតិ ទោះបី ខ្វះ កម្លាំងសម្ភារ: តែ មិនព្រមចាញ់ចិត្ដ គឺ មិនយក យស ទៅដូរនឹង ស័ក្ដិ, មិន ដូរ សក្ដា នឹង របស់ ដូចជា អាសន: អាម៉ាស់ក្ដ្ដ នៅក្នុង រដ្ឋ សភា ដើម្បី ក្រាន់តែ រស់រស់ ជា អាមាត្យឃ្លាន ហើយ នាំគ្នាប្រើ សខិលសម្ភាសា[8] ក្នុងគោលបំណង បញ្ជ្ជោតរាស្ត្ដ នៅពេល ជ្រោះ ផ្ទោត ហើយ ប្ដូម ជា អ្នកសង្គ្រោះជាតិ ក្នុង យុទ្ធសាស្ត្ដ្ដ ឃ្លាន គឺ អន្ដរប្ដតិបត្ដិការកិច្ច និង ស្ងប់ភាព នៃយុទ្ធសាស្ត្ដ ដែលមាន គណបក្សកាន់អំណាច ជា ដៃគូ ហើយ នាំគ្នា ក្ដ្ដ ប់មេក្ដ ប់ពង ទុក ខ្មែរមិនខ្លាចឃ្លាន និង ហ៊ុន សែន ជា អ្នករើសអើងពូជសា សន៍ និង អ្នកអច្ចន្ត្ដិនិយម។

[7] សង្គ្រោបមូល; សង្គ្រោបការណ៍ គឺ ប្ដ្ដ ភពនៃកំហឹង។ សង្គ្រោប; ការក្ដ្ដ ក្ដ្ដ ចិត្ដ។
[8] សខិលសម្ភាសា ឬ សខិលភាសា; សម្ដ្ដ ីដែលនាំអោយបានជាទ្ដ ីស្ដ្ដ ឡាញ់។